**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ប្រមូលទិន្នន័យបាន ៦០%ហើយ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- រោងចក្រវេចខ្ចប់ និងច្រកវ៉ាក់សាំងកូវីដ១៩នៅកម្ពុជា នឹងចេញជារូបរាងនៅចុងឆ្នាំនេះ ឬដើមឆ្នាំក្រោយ
- អគ្គនាយកដ្ឋានពន្ធដារប្រមូលពន្ធបាន៥១២លានដុល្លារកើនជាង ២២% រយៈពេលពីរខែដំបូងឆ្នាំ២០២២
- កម្ពុជា សម្រេចបានការនាំចេញអង្ករជាង១០ម៉ឺនតោន ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២២
- កម្ពុជារំពឹងរកបានចំណូល៣៥លានដុល្លាពីវិស័យបនល្បែងនៅឆ្នាំ២០២២
- អត្រាអ្នកអត់ការងារធ្វើរបស់ប្រទេសសិង្ហបូរីធ្លាក់ចុះដល់កម្រិតមុនជំងឺរាតត្បាត
- តំបន់ប្រើប្រាស់ប្រាក់អឺរ៉ូបានរឹតបន្តឹងគោលនយោបាយសារពើពន្ធនៅឆ្នាំ២០២៣ដើម្បីត្រៀមខ្លួនក្នុងការបញ្ចៀសសង្គ្រាម អ៊ុយក្រែន
- ចិនបានក្លាយជាប្រទេសឈានមុខគេលើពិភពលោកក្នុងការនាំចេញរថយន្តអគ្គីសនី
- បារាំងចង់ឲ្យសហភាពអឺរ៉ុបកំណត់កញ្ចប់បំណុលថ្មី ខណៈពេលសង្គ្រាមអ៊ុយក្រែនតានតឹង
- អូស្ត្រាលីនិងឥណ្ឌាកំពុងឆ្ពោះទៅរកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដើម្បីកាត់បន្ថយការពឹងផ្អែកលើចិន
- ឥណ្ឌាសម្លឹងឃើញឱកាសទិញប្រេងរុស្ស៊ីក្នុងតម្លៃទាប


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែមីនា ឆ្នាំ២០២២ លេខ ៖ ១១១

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ ប្រមូលទិន្នន័យបាន ៦០% ហើយ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស




*ដោយ ខេមបូណ្ណមីស*

ការធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២នេះ បានធ្វើជាលើកទី២ បន្ទាប់ពីបានធ្វើជាលើកដំបូងនៅឆ្នាំ២០១១ ហៅថា ជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ២០១១។ ទិន្នន័យជំរឿនសេដ្ឋកិច្ចមានសារៈសំខាន់បំផុត ដើម្បីឆ្លើយតបសេចក្តីត្រូវការប្រើប្រាស់ទិន្នន័យ សម្រាប់ជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច បរិស្ថាន សង្គម វប្បធម៌ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា និងផ្តល់សូចនាករសម្រាប់ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០១៦-២០៣០។

ការធ្វើជំរឿនសេដ្ឋកិច្ច ជាការងារដ៏ធំ និងមានសារៈសំខាន់ដូចជា អាចធ្វើបច្ចុប្បន្នភាពចំនួនអង្គភាពទាំងខ្នាតតូច មធ្យម និង ខ្នាតធំ នៅទូទាំងប្រទេសកម្ពុជា និង អាចធ្វើការវាស់វែងអំពីគណនីភាពជាដើម។ ក្រសួងផែនការបានចុះប្រមូលព័តមានពីអង្គភាពសេដ្ឋកិច្ចទូទាំងប្រទេសគឺចាប់តាំងពីថ្ងៃទី ០១ ខែមីនា មកម្ល៉េះ ហើយគិតមកទល់ពេលនេះ ប្រមូលទិន្នន័យបានប្រហែល ៦០% និងកំពុងបន្តការប្រមូលដើម្បីឱ្យចប់តាមការកំណត់ដែលបានគ្រោងទុក។

ជំរឿនសេដ្ឋកិច្ចនេះ ធ្វើឡើងរយៈពេល ១០ឆ្នាំម្តង ហើយជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២ នឹងត្រូវធ្វើឡើងចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ នៅទូទាំងប្រទេសដោយត្រូវប្រើប្រាស់មន្ត្រីសម្ភាសន៍សរុបចំនួនប្រមាណ៥ពាន់នាក់។ ផ្អែកលើរបាយការណ៍លទ្ធផលបឋមស្តីពីការស្រង់បញ្ជីអង្គភាពសេដ្ឋកិច្ច នៅតាមរាជធានីខេត្តទាំង២៥ បានឱ្យដឹងថា មានចំនួនអង្គភាពសេដ្ឋកិច្ចសរុបជាង ៧សែន៤ម៉ឺន ទីតាំងមូលដ្ឋាន នៅឆ្នាំ២០២១ ក្នុងទូទាំងប្រទេស។ ចំនួនអង្គភាពសេដ្ឋកិច្ច បានកើនឡើងប្រមាណ ៤៧% បើធៀបនឹងឆ្នាំ២០១១ (ជំរឿនសហគ្រាសឆ្នាំ២០១១) ហើយបានកើនឡើងប្រមាណ ៤៥% បើធៀបនឹងឆ្នាំ២០១៤ (ទិន្នន័យអង្កេតចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤)។

ជាមួយគ្នានេះ ទិន្នន័យទាំងអស់ដែលបានមកពីជំរឿនសេដ្ឋកិច្ច គឺជាទិន្នន័យពិតប្រាកដ ដែលបានមកពីគ្រប់អង្គភាពសេដ្ឋកិច្ច សហគ្រាស សិប្បកម្ម អាជីវកម្ម លក់ដុំ លក់រាយ និងសេវាកម្មផ្សេងៗ។ ហើយលទ្ធផលទិន្នន័យដែលបានមកពីការធ្វើជំរឿនសេដ្ឋកិច្ច នឹងត្រូវបានប្រើប្រាស់ដ៏ទូលំទូលាយនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។*

## រោងចក្រវេចខ្ចប់ និងច្រកវ៉ាក់សាំងកូវីដ១៩នៅកម្ពុជា នឹងចេញជារូបរាងនៅចុងឆ្នាំនេះ ឬដើមឆ្នាំក្រោយ



*ដោយ Kampucheathmey*

រដ្ឋលេខាធិការក្រសួងសុខាភិបាលបានមានប្រសាសន៍ថា រោងចក្រវេចខ្ចប់ និងច្រកវ៉ាក់សាំងកូវីដ១៩ អាចនឹងចេញជារូបរាងនៅចុងឆ្នាំ២០២២នេះ ឬនៅដើមឆ្នាំ២០២៣ខាងមុខនេះ។ រាជរដ្ឋាភិបាល នឹងរៀបចំរោងចក្រវេខ្ចប់ និងច្រកវ៉ាក់សាំងនៅក្នុងប្រទេសកម្ពុជា។ ក្រសួងសុខាភិបាលបានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន និងភាគីចិនជាបន្តបន្ទាប់ ដោយទទួលបានលទ្ធផលជាវិជ្ជមានមួយដំណាក់កាលហើយ។ ដូច្នេះ នឹងធ្វើការពិភាក្សាបន្តបន្ទាប់ទៀត។ ដូច្នេះការវិនិយោគរោងចក្រវេចខ្ចប់និងច្រកវ៉ាក់សាំងកូវីដ១៩នេះ អាចនឹងចេញជាលទ្ធផលនៅចុងឆ្នាំនេះឬនៅដើមឆ្នាំក្រោយ។ កាលពីចុងឆ្នាំ២០២១កន្លងទៅ ប្រមុខរាជរដ្ឋាភិបាលបានអះអាងថា កម្ពុជានឹងបើកដំណើរការរោងចក្រផលិតវ៉ាក់សាំងការពារជំងឺកូវីដ១៩ប្រភេទ «ស៊ីណូហ្វាម» របស់ប្រទេសចិននៅក្នុងស្រុកជាលើកដំបូងនាឆ្នាំ២០២២នេះ។ នៅពេលដែលកម្ពុជា មានរោងចក្រផលិតវ៉ាក់សាំងក្នុងស្រុក នោះក្ដីកង្វល់អំពីបញ្ហាកង្វះវ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋដែលជាទិសដៅអាទិភាព នឹងលែងជាបញ្ហាទៀតហើយ ពីព្រោះកម្ពុជានឹងអាចផ្គត់ផ្គង់បានដោយខ្លួនឯងផ្ទាល់ និងអាចកាត់បន្ថយការដឹកជញ្ជូនតាមផ្លូវឆ្ងាយ ជាពិសេស វ៉ាក់សាំងអាចលក់ក្នុងតម្លៃសមរម្យជាងការបញ្ជាទិញពីក្រៅប្រទេស៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ Kampucheathmey ចេញផ្សាយថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។*

## អគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធបានប្រមាណ ៥១២លានដុល្លារអាមេរិក កើនជាង ២២% រយៈពេលពីរខែដំបូងឆ្នាំ២០២២



GDT Director General Kong Vibol

*ប្រភព៖ Khmer Times ២០២១*

អគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធបានប្រមាណ ៥១២លានដុល្លារអាមេរិក កើនឡើងជាង ២២% គិតក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២២ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ នេះបើយោងសេចក្តីប្រកាសព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកុម្ភៈ ឆ្នាំ២០២២ និងទិសដៅអនុវត្តន៍ការងារបន្ត។

ចំណូលពីពន្ធសំខាន់ៗ ០៥ប្រភេទ បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ ធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១ ក្នុងនោះរួមមាន៖ ពន្ធលើប្រាក់ចំណូលមានចំនួន ១៩០,១៥ប៊ីលានរៀល កើនឡើង ២៣,៦១ប៊ីលានរៀល ឬ ១៤,១៨%, អាករលើតម្លៃបន្ថែម មានចំនួន ២៥២,៧៨ប៊ីលានរៀល កើនឡើង ១៣,២៣ប៊ីលានរៀល ឬ ៥,៥២%, អាករពិសេសមានចំនួន ១០៥,៦៧ប៊ីលានរៀល កើនឡើង ១៥,៥០ប៊ី

លានរៀល ឬ ១៧,១៩%, ពន្ធលើប្រាក់បៀវត្សមានចំនួន ៩៨,៤២ប៊ីលានរៀល កើនឡើង ១៨,៥១ប៊ីលានរៀល ឬ ២៣,១៧% និងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យមានចំនួន ៦៣,២៣ប៊ីលានរៀល កើនឡើង ៩,១៨ប៊ីលានរៀល ឬ ១៦,៩៨%។

អគ្គនាយកដ្ឋានពន្ធដារ នឹងបន្តពង្រឹងការអនុវត្តគោលនយោបាយសារពើពន្ធ និងវិធានការរដ្ឋបាល ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធឱ្យបានគ្រប់តាមផែនការនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ក្នុងចំនួន ១១ ៤១៩,១៣ ប៊ីលានរៀល ឬប្រមាណ ២,៨២ប៊ីលានដុល្លារអាមេរិក។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Khmer Times ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២*

## កម្ពុជា សម្រេចបានការនាំចេញអង្ករជាង១០ម៉ឺនតោន ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២២



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ Chor Sokunthea*

យោងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីពេលថ្មីៗ បានឱ្យដឹងថា៖ កម្ពុជា បានកត់ត្រាកំណើននៃការនាំចេញអង្ករចំនួន ១០៣ ០៥៨តោន រួមទាំងអង្ករក្រអូបគ្រប់ប្រភេទផងដែរ ក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០២២ ពោលគឺកើនឡើងចំនួន ២៦ ៨៣៦តោន បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ដែលមានចំនួន ៧៦ ២២២តោន។

ការនាំចេញអង្ករ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ មានចំនួនសរុប ៥០ ០២២តោន កើនឡើងចំនួន ៨ ០៧៣តោន ឬ ១៩,២៤% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១ ដែលមានចំនួន ៤១ ៩៤៩តោន។

ប្រទេសចិន គឺជាទីផ្សារចម្បងសម្រាប់ការនាំចេញអង្កររបស់កម្ពុជា ក្នុងបរិមាណសរុបចំនួន ៥៦ ៣៨៥តោន ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២២ ខណៈ ការនាំចេញទៅកាន់ប្រទេសចំនួន ២០ នៅក្នុងសហភាពអ៊ឺរ៉ុបមានបរិមាណសរុប ២៦ ៥០៧តោន និងប្រទេសសមាជិកអាស៊ានចំនួន ៣ មានចំនួន ៩ ៣៧០តោន។ ដោយឡែក ការនាំចេញអង្ករទៅកាន់ប្រទេសចំនួន ១៦ ផ្សេងទៀត បានធ្លាក់ចុះមកនៅត្រឹម ១០ ៧៩៦តោន ឬ ថយចុះ ១៩,២៣%។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Khmer Times ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២*

## រដ្ឋាភិបាលបានសម្រេចទទួលស្គាល់ជាផ្លូវការសមាគមត្រចៀកកាំ ដើម្បីជំរុញការនាំចេញ



*ដោយ Postkhmer*

សមាគមត្រចៀកកាំខ្មែរ ត្រូវបានរដ្ឋាភិបាលទទួលស្គាល់ជាផ្លូវការ។ មកដល់ពេលនេះ សមាគមកំពុងខិតខំធ្វើការគ្រប់បែបយ៉ាងដើម្បីជួយជំរុញ និងអភិវឌ្ឍសកម្មភាពនៃការរៀបចំផ្ទះ ការចិញ្ចឹម និងកែច្នៃ

ផលិតផលពីទឹកមាត់សត្វត្រចៀកកាំខ្មែរឱ្យមានគុណភាពកម្រិតស្តង់ដា។

សម្បុកត្រចៀកកាំ គឺជាផលិតផលដែលមានការនិយមចូលចិត្តទទួលទានច្រើនបំផុតនៅលើពិភពលោក។ ទោះបីពេលនេះផលិតផលសម្បុកត្រចៀកកាំខ្មែរនៅមិនទាន់ទទួលបានតម្លៃខ្ពស់ ប៉ុន្តែសម្រាប់ទីផ្សារគឺមិនមានបញ្ហាទេ។

សមាគមត្រចៀកកាំខ្មែរ បាននិងកំពុងជំរុញ និងលើកទឹកចិត្តចំពោះការវិនិយោគលើការចិញ្ចឹម និងអភិវឌ្ឍផ្ទះត្រចៀកកាំ, ការពង្រឹងគុណភាពផលិតផលពីទឹកមាត់ត្រចៀកកាំ, ការផ្តល់ការសិក្សាស្វែងយល់ ដំណោះស្រាយ និងចែករំលែកចំណេះដឹងពីបច្ចេកទេសក្នុងការចិញ្ចឹម និងអភិរក្ស, និងការស្វះស្វែងរកទីផ្សារនាំចេញទឹកមាត់ត្រចៀកកាំទៅទីផ្សារអន្តរជាតិ ពិសេសប្រទេសចិន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន បានចូលជាធរមានហើយ ហេតុនេះឱកាសសម្រាប់ការនាំចេញសម្បុកត្រចៀកកាំខ្មែរទៅលក់នៅចិនដែលជាទីផ្សារធំជាងគេលើពិភពលោក។ ក្នុង១ឆ្នាំៗ ប្រទេសចិនមានតម្រូវការផលិតផលសម្បុកត្រចៀកកាំរាប់ពាន់តោន រីឯការផ្គត់ផ្គង់នៅខ្វះជាង ១ ០០០ តោនជារៀងរាល់ឆ្នាំ។ ការប្រមូលផលសម្បុកត្រចៀកកាំនៅកម្ពុជានៅមានបរិមាណតិចជាង ១០០ តោននៅឡើយ ក្នុង១ឆ្នាំៗ ប៉ុន្តែកម្ពុជាជាប្រទេសដែលមានធម្មជាតិល្អគ្រប់គ្រាន់សម្រាប់ការវិនិយោគលើផ្ទះត្រចៀកកាំ។ បច្ចុប្បន្នសម្បុកត្រចៀកកាំនៅកម្ពុជាមិនទាន់សម្អាត មានតម្លៃជាមធ្យមចន្លោះពី ៦៥០-៧០០ ដុល្លារក្នុង ១ គីឡូក្រាម និងសម្អាតហើយមានតម្លៃចន្លោះពី ១ ៦០០ ដុល្លារទៅជាង ២ ០០០ ដុល្លារ។ ចំណែកនៅប្រទេសម៉ាឡេស៊ី ផលិតផលសម្បុកត្រចៀកកាំមិនទាន់សម្អាតអាចមានតម្លៃចន្លោះពី៨០០-១ ០០០ដុល្លារឯណោះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកន្លងមកបានឱ្យដឹងថា កម្ពុជាបានដាក់សំណើទៅរដ្ឋាភិបាលចិនដើម្បីស្នើសុំនាំចេញផលិតផលកសិកម្មដូច ផ្លែមៀន ប៉ៃលិន ម្រេច ទុរេន ក្រូចត្លុង និងសម្បុកត្រចៀកកាំ ជាដើម។ ក្រុមការងាររបស់ក្រសួងកសិកម្មកំពុងតែធ្វើការជាមួយផ្នែកឯកជន និងអាជ្ញាធរប្រទេសចិន ដើម្បីនាំចេញផលិតផលពីទឹកមាត់ត្រចៀកកាំទៅប្រទេសចិន។ ទោះយ៉ាងណាផែនការនេះមានឧបសគ្គធំៗចំនួន ២ គឺការចរចាជាមួយភាគីចិន និងបញ្ហាក្នុងស្រុក។ បញ្ហាខាងក្រៅគឺភាគីចិនបានកំណត់គោលការណ៍ក្នុងការចរចា ១ដង ១មុខទំនិញ ចំណែកបញ្ហាខាងក្នុងគឺសមត្ថភាពកែច្នៃដែលនៅមិនទាន់ស្របតាមស្តង់ដាដែលចិនចង់បាន។ តាមការស្រាវជ្រាវ គឺកម្ពុជានៅមិនទាន់មានការរៀបចំរោងចក្រកែច្នៃណាមួយ ដែលមានកម្រិត ISO នៅឡើយទេ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Postkhmer ចេញផ្សាយថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២។*

## ARDB ផ្តល់ឥណទានចម្បងសម្រាប់សាងសង់ឃ្លាំងស្តុក និងឡសម្ងួតស្រូវ



*ដោយ postkhmer*

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB ) ផ្តល់ឥណទានចម្បងដល់វិស័យស្រូវអង្ករសម្រាប់ការសាងសង់ឃ្លាំងស្តុក និងឡសម្ងួតស្រូវក្នុងទំហំទឹកប្រាក់ ៣០ លានដុល្លារនៅក្នុងខេត្តចំនួន ៤ រួមមាន ខេត្តបាត់ដំបង កំពង់ធំ ព្រៃវែង និងខេត្តតាកែវ។ ARDB ក៏គ្រោងនឹងបង្កើតការិយាល័យចល័តនេះឱ្យបាន ៥ ខេត្តទៀត

ខណៈបច្ចុប្បន្នខ្លួនបានបង្កើត ៩ ខេត្តរួចមកហើយ ដោយភាគច្រើននៅខេត្តជុំវិញបឹងទន្លេសាប និងខេត្តឆ្ងាយៗ ដូចជា ស្ទឹងត្រែង ក្នុងគោលបំណងបង្កិតសេវាកម្មទៅជិតអតិថិជន ខណៈបច្ចុប្បន្នការពឹងផ្អែកលើការិយាល័យកណ្តាលតែមួយ គឺនៅឆ្ងាយពីអ្នកមានតម្រូវការសេវាកម្មនៅតាមបណ្តាខេត្តមួយចំនួន។

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាបានប្រាប់ថា កម្ពុជាជាប្រទេសដែលមានសក្តានុពល ក្នុងការដាំដុះស្រូវ ដូចនេះការសាងសង់ឃ្លាំងស្តុក និងឡសម្ងួត គឺជាការវិនិយោគមួយដែលត្រឹមត្រូវបំផុត។ វានឹងជួយជំរុញការកែច្នៃ និងនាំចេញជាផ្លូវការនៃវិស័យស្រូវអង្កររបស់យើង។ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម តែងតែផ្តល់ឥណទានដល់ក្រុមហ៊ុនសមាជិកសហព័ន្ធ ស្រូវអង្ករកម្ពុជា, រោងម៉ាស៊ីនកិនស្រូវ, ក្រុមហ៊ុននាំចេញអង្ករ ក៏ដូចជាការជួយពង្រឹងសមត្ថភាពរោងម៉ាស៊ីនក្នុងស្រុកយើងឱ្យមានលទ្ធភាពប្រកួតប្រជែង និងរស់រានក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ជាពិសេសបង្កើនចំនួនឡសម្ងួត ឃ្លាំង និងការកែច្នៃនាំចេញ។

អ្នកនាំចេញអង្ករ នៅស្រុកថ្មគោល ខេត្តបាត់ដំបង និងជាសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា បានប្រាប់ថា ប៉ុន្មានឆ្នាំមុនការខ្វះខាតឃ្លាំងស្តុក និងឡសម្ងួតស្រូវជាច្រើនដែលធ្វើឱ្យនៅរដូវប្រមូលផលម្តងៗតម្លៃស្រូវចុះថោកខ្លាំង។ ឃ្លាំងស្តុក និងឡសម្ងួតស្រូវមានកាន់តែច្រើន វានឹងបង្កលក្ខណៈងាយស្រួល ដោយសារយើងជាអ្នកនាំចេញមិនចាំបាច់ព្រួយបារម្ភពីការខ្វះខាតកន្លែងស្តុក និងឡសម្ងួត ហើយកសិករអាចលក់ស្រូវបានក្នុងតម្លៃសមរម្យ។ ចំពោះឈ្មួញក៏លក់ចេញបានតម្លៃប្រកួតក្នុងទីផ្សារផងដែរ។ ប៉ុន្តែបញ្ហាដែលប្រជាកសិករ និងក្រុមឈ្មួញកំពុងជួបប្រទះនាពេលនេះ គឺថ្លៃដើមផលិតកើនឡើង ដូចប្រេង និងជីកសិកម្មជាដើម។

យោងតាមរបាយការណ៍ពីក្រសួងកសិកម្ម ក្នុងឆ្នាំ ២០២១ កម្ពុជាបាននាំចេញអង្ករទៅទីផ្សារអន្តរជាតិក្នុងបរិមាណសរុប ៦១៧ ០៦៩ តោន ថយចុះ ១០,៦៨% បើធៀបនឹងបរិមាណនាំចេញឆ្នាំ ២០២០ ដែលមាន ៦៩០ ៨២៩ តោន។ ដោយឡែកក្នុងរយៈពេល ២ ខែដើមឆ្នាំ ២០២២ កម្ពុជាបាននាំចេញអង្ករទៅទីផ្សារអន្តរជាតិសរុប ១០៣ ០៥៨ តោន កើនឡើង ៣៥,២១%បើធៀបនឹងបរិមាណនាំចេញរយៈពេល ២ ខែឆ្នាំ២០២១ មានចំនួន៧៦ ២២២តោន៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ postkhmer ចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។*

## ដំឡើងពន្ធថ្នាំជក់ដើម្បីកាត់បន្ថយការជក់បារី និងការជួញដូរផលិតផលថ្នាំជក់ខុសច្បាប់



*ដោយ Campost*

ការដំឡើងពន្ធទៅលើផលិតផលដែលមានហានិភ័យខ្ពស់ដល់សុខភាព ដូចជាផលិតផលថ្នាំជក់ ជារឿងដែលល្អបំផុតក្នុងពេលនេះ ធ្វើឱ្យកម្ពុជាទទួលបានអត្ថប្រយោជន៍យ៉ាងក្រាស់ក្រែល ពោលគឺមិនត្រឹមតែទទួលបានចំណូលពន្ធរដ្ឋបន្ថែមប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យអ្នកឈប់ជក់បារីមានសុខភាព និងផលិតភាពការងារល្អប្រសើរជាងមុន។

សម្ព័ន្ធត្រួតពិនិត្យថ្នាំជក់អាស៊ីអាគ្នេយ៍ បានបញ្ជាក់ថា ការដំឡើងពន្ធថ្នាំជក់ ធ្វើឱ្យតម្លៃថ្នាំជក់កើនឡើង និងកាត់បន្ថយលទ្ធភាពទិញបាន ហើយវាជាវិធីសាស្ត្រមានប្រសិទ្ធភាពបំផុតក្នុងការកាត់បន្ថយការប្រើប្រាស់ថ្នាំ

ជក់ និងជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ។ ក្រៅពីធ្វើឱ្យជីវិតប្រជាពលរដ្ឋស្លាប់រាប់ម៉ឺននាក់ជារៀងរាល់ឆ្នាំ ថ្នាំជក់ក៏បានធ្វើឱ្យកម្ពុជាខាតបង់សេដ្ឋកិច្ចគិតជាថវិកា ប្រមាណ ២,៧ ទ្រីលានរៀល ស្មើនឹង ៦៦៣ លានដុល្លារ ដែលស្មើនឹង៣%នៃផលិតផលក្នុងស្រុកសរុប (GDP)។ អត្រាពន្ធថ្នាំជក់នៅកម្ពុជាបច្ចុប្បន្នគឺត្រឹមតែ ២៥% ទៅ៣០%។ ជាមធ្យមបារីមួយកញ្ចប់មានតម្លៃតិចជាង ១ដុល្លារសហរដ្ឋ ធ្វើឱ្យលទ្ធភាពទិញបានកាន់តែខ្ពស់។

*តើអ្វីជាមូលហេតុពិតប្រាកដដែលនាំឱ្យមានការជួញដូរផលិតផលថ្នាំជក់ខុសច្បាប់ ?*

តាមការសន្និដ្ឋាន ប្រហែលជា១១,៦%នៃទីផ្សារបារីលើសកលលោក គឺជាពាណិជ្ជកម្មខុសច្បាប់ ហើយភាគច្រើន កើតមាននៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ដែលបារីមានតម្លៃទាប។ ទីផ្សារបារីខុសច្បាប់នៅប្រទេសដែលហូតពន្ធបារីទាប និងតម្លៃបារីទាប មានច្រើនជាងប្រទេសដែលហូតពន្ធបារីខ្ពស់ និងតម្លៃបារីខ្ពស់ជាង។ មូលហេតុបណ្តាលឱ្យមានការជួញដូរផលិតផលថ្នាំជក់ខុសច្បាប់គឺមិនពាក់ព័ន្ធទៅនឹងកត្តាតម្លៃទេ ប៉ុន្តែ ពាក់ព័ន្ធទៅនឹងអំពើពុករលួយ ភាពកំសោយនៃច្បាប់ពន្ធនិងការពង្រឹងច្បាប់ទាក់ទងនឹងពន្ធ ព្រមទាំងការចូលរួមរបស់ក្រុមហ៊ុនថ្នាំជក់ និងបណ្តាញឧក្រិដ្ឋកម្មផ្សេងទៀត។

នៅប្រទេសម៉ាឡេស៊ី ទោះបីជាគ្មានការដំឡើងពន្ធថ្នាំជក់ចាប់តាំងពីឆ្នាំ២០១៦ ដល់២០២១ក៏ដោយ ក្រុមហ៊ុនថ្នាំជក់នៅតែបន្តលើកពីបញ្ហាការកើនឡើងនៃការជួញដូរផលិតផលថ្នាំជក់ខុសច្បាប់ ដើម្បីជម្រុញរាជរដ្ឋាភិបាលឱ្យដកចេញនូវផែនការដំឡើងពន្ធថ្នាំជក់។ ជារួមមក ការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ទៅក្នុងវិធានការពន្ធថ្នាំជក់ និងវិធានការដទៃទៀត បានរារាំងដល់ការគាំទ្រលើវិស័យសុខភាពសាធារណៈ នៅក្នុងប្រទេសម៉ាឡេស៊ី។ នៅប្រទេសសាំងហ្គាពួរ រដ្ឋាភិបាលទទួលបានជោគជ័យលើការរក្សាអាជីវកម្មបារីខុសច្បាប់ឱ្យនៅកម្រិតទាបខ្លាំង ទោះបីជាបារីនៅក្នុងប្រទេសនេះមានតម្លៃខ្ពស់បំផុតនៅក្នុងតំបន់អាស៊ានក៏ដោយ។ ការដំឡើងពន្ធនឹងនាំឱ្យតម្រូវការបារីមានការធ្លាក់ចុះសូម្បីតែនៅពេលដែលផលិតផលបារីខុសច្បាប់ចរាចរនៅលើទីផ្សារក៏ដោយ។

ដូច្នេះ ការគេចពន្ធ នឹងមិនធ្វើឱ្យបាត់បង់ប្រសិទ្ធភាពនៃការដំឡើងពន្ធ សម្រាប់សុខភាពសាធារណៈ និងចំណូលពន្ធរដ្ឋនោះទេ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ Campost ចេញផ្សាយថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។*

## ការនាំចេញម្រេចនៅតែសម្រេចបានកំណើនខ្ពស់ក្នុងអត្រា៣ខ្ទង់និងតម្លៃទីផ្សារថេរ



*រូបភាព៖ សមាគមន៍ម្រេចកំពតកម្ពុជា*

នៅ ២ខែដំបូងឆ្នាំនេះកសិផលជាច្រើនមុខដែលកម្ពុជាបាននាំចេញ គឺមានស្វាយ និងចេកអំបូងលឿងជាដើម សុទ្ធតែថយចុះ គឺមានតែម្រេចប៉ុណ្ណោះ ដែលនៅរក្សាបានកំណើននាំចេញខ្ពស់ជាងគេ មានជាង ៩០០តោន កើនឡើងជិត ៤០០% បើប្រៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២១។

អ្នកដាំម្រេច នៅខេត្តត្បូងឃ្មុំ បានកត់សម្គាល់ឃើញថា នៅដើមឆ្នាំ២០២២ ម្រេច មានតម្លៃ ១៦ ០០០រៀល ក្នុង១គីឡូក្រាម ក្រោយមកតម្លៃម្រេចក៏បានធ្លាក់ចុះតិច

តួចមកនៅត្រឹម ១៥ ០០០ រៀល ចាប់ពីមានការផ្ទុះឡើងនៃរវាងរុស្ស៊ី និងអ៊ុយក្រែន។ ម្រេចរបស់ខេត្តត្បូងឃ្មុំ បាននាំចេញទៅប្រទេសវៀតណាម កាលណាប្រទេសវៀតណាម មានបញ្ហានាំចេញម្រេច នោះវាក៏អាចប៉ះពាល់ដល់ទីផ្សារម្រេចកម្ពុជាខ្លះៗដែរ។ សង្គ្រាមអ៊ុយក្រែន ហាក់មិនមែនជាឧបសគ្គធំឡើយ សម្រាប់ការនាំចេញម្រេច។ ឆ្នាំ២០២២នេះ ទីផ្សារម្រេចនឹងកាន់តែប្រសើរ ព្រោះតម្រូវការកាន់តែទូលាយ។ បញ្ហាដែលព្រួយបារម្ភនោះគឺបញ្ហាអាកាសធាតុ ពិសេសការខ្វះខាតទឹកស្រោចស្រព និងបញ្ហាតម្លៃប្រេងឡើងថ្លៃ ដែលធ្វើឱ្យកសិករត្រូវចំណាយថ្លៃដើមខ្ពស់។

ប្រធានសមាគមម្រេចកំពត ក៏បានគូសបញ្ជាក់ថា រយៈពេល២ខែនេះ សមាគមបាននាំចេញម្រេចកំពត ក្នុងបរិមាណ៦តោន ទៅអឺរ៉ុប ដោយក្នុងនោះ សម្រាប់ម្រេចខ្មៅ មានតម្លៃ ១៥ដុល្លារ ក្នុង១គីឡូក្រាម។ រីឯ ម្រេចក្រហម មានតម្លៃ ២៥ដុល្លារ ក្នុង១គីឡូក្រាម។ ចំណែកឯ ម្រេចសវិញ មានតម្លៃ ២៥ដុល្លារ ទៅ២៨ដុល្លារ ក្នុង១គីឡូក្រាម។ សម្រាប់ស្ថានភាពនៃការដាំដុះដំណាំម្រេច នាខេត្តកំពតវិញមិនមានបញ្ហាអ្វីនោះទេ។ ទីផ្សារម្រេច នៅដើមឆ្នាំ២០២២នេះ ក៏មិនខុសគ្នានោះដែរពីឆ្នាំមុន ព្រោះកសិករដាំម្រេចបានចងក្រងជាសហគមន៍ និងបានចុះកុងត្រាជាមួយក្រុមហ៊ុននាំចេញស្រាប់ ទើបធ្វើឱ្យកសិករមិនបារម្ភពីការឡើងចុះនៃតម្លៃម្រេច។

នៅឆ្នាំ២០២១ កន្លងទៅ កម្ពុជាបាននាំចេញម្រេច ក្នុងបរិមាណ ២៨ ០០០តោន ទៅកាន់ទីផ្សារសំខាន់ៗ ដូចជា តំបន់អឺរ៉ុប និងតំបន់អាស៊ាន ជាដើម។ ដោយឡែកនារយៈពេល ២ខែដំបូង ក្នុងឆ្នាំ២០២២នេះ កម្ពុជាបាននាំចេញម្រេច ជាង៩០០តោន ក្នុងចំណោមកសិផល សរុបជាង១ ៣០០ ០០០តោន៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។*

## កម្ពុជាមានសក្តានុពលលើការដាំកាកាវ ទីផ្សារតម្លៃខ្ពស់



*ដោយ ខេមបូណូមីស*

ទោះបី កាកាវជាដំណាំថ្មីសម្រាប់កម្ពុជា តែបច្ចុប្បន្នគេសង្កេតឃើញថាប្រជាកសិករ ពេញនិយមដាំដំណាំមួយនេះស្ទើរគ្រប់ខេត្ត ព្រោះមានទីផ្សារខ្ពស់ពិសេសនៅទីផ្សារតំបន់អឺរ៉ុប តែម្តង។ បច្ចុប្បន្ន គ្រាប់កាកាវ ១តោន មានតម្លៃរហូតដល់ ២ពាន់ដុល្លារ។

ប្រធានអគ្គនាយកក្រុមហ៊ុនផលិតឱសថ PPM និងអ្នកវិនិយោគលើការដាំដុះដំណាំកាកាវ នៅខេត្តរតនគិរីដែរនោះ បានបញ្ជាក់ថា ដំបូងឡើយ លោកគ្រាន់តែសាកល្បងដាំបន្តិចបន្តួចប៉ុណ្ណោះ តែក្រោយពីមានតម្រូវការកាន់តែច្រើន លោកបានពង្រីកការដាំដុះរហូត ៣០ហិកតា។ កាកាវ កាន់តែមានតម្រូវការច្រើន ក៏ប៉ុន្តែសម្រាប់កម្ពុជាវិញ ការដាំដុះហាក់មិនទាន់គ្រប់តាមតម្រូវការនៅឡើយទេ បើទោះបី ការដាំដំណាំនេះ និងការរក្សាទុកគ្រាប់ជាដើម មានភាពងាយស្រួល។ ស្ថិតលើផ្ទៃដី ៣០ហិកតា ជាមធ្យមអាចប្រមូលផលកាកាវប្រហែល២តោន ក្នុង១ឆ្នាំ។

រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្លាប់បានគូសបញ្ជាក់ថា កាកាវ គឺជាដំណាំថ្មីមួយប្រភេទ ដែលក្រសួងកំពុងសិក្សានៅឡើយ។ ក៏ប៉ុន្តែក្រសួង នៅតែបន្តសិក្សាបន្ថែមទៀត លើដំណាំ

នេះ ព្រោះតែវាក៏មានទីផ្សារមិនចាញ់ដំណាំកាហ្វេនោះដែរ។ កាការជាប្រភេទដំណាំងាយស្រួលក្នុងការដាំ លក្ខខណ្ឌអាកាសធាតុសមប្រកប សម្រាប់ដំណាំប្រភេទនេះ គឺត្រូវការអាកាសធាតុក្ដៅហើយសើម ជាដំណាំមិនប្រកាន់រដូវ តែមិនអាចដាំបានក្នុងតំបន់ទំនាបដក់ទឹកបានទេ វាត្រូវការទឹកពី ៧០ទៅ៨០% ក្នុងការស្រោចស្រព និងការមើលថែទាំឱ្យបានដិតដល់ដូចប្រភេទដំណាំខ្លះផងដែរ បើមិនមានទឹកគ្រប់គ្រាន់ទេ វាប្រឈមនឹងហានិភ័យមួយចំនួន ដូចជាងាប់ដើម ក្រិនដើម ការលូតលាស់មិនល្អ និងការឱ្យផលយឺត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។*

## ឆ្នាំនេះ កម្ពុជានឹងមិនខ្វះអំបិលប្រើនោះទេ



*ដោយ ខេមបូណ្ឌមីស(កសិករប្រមូលអំបិលនៅខេត្តកំពត)*

ប្រធាននាយកដ្ឋានកិច្ចការសិប្បកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានវាយតម្លៃថា កម្ពុជានឹងអាចផលិតអំបិលបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុក ដោយមិនចាំបាច់នាំចូលពីក្រៅប្រទេសនោះឡើយ ប្រសិនបើអាកាសធាតុអំណោយផលល្អ។ នៅឆ្នាំនេះកម្ពុជានឹងអាចផលិតអំបិលបានចន្លោះពី ៧០ ០០០ ទៅ៨០ ០០០តោន ប្រហាក់ប្រហែលនឹងឆ្នាំមុន។ បច្ចុប្បន្ន កម្ពុជាមានអំបិលក្នុងស្តុកជាង ១០ ០០០តោនរួចទៅហើយ។ ពាក់ព័ន្ធរឿងតម្លៃអំបិលនៅឆ្នាំនេះ គឺពុំមានការប្រែប្រួលនោះទេបើធៀបនឹងឆ្នាំមុន ដោយអំបិលក្នុង១បាវទម្ងន់៥០គីឡូក្រាមលក់ចេញក្នុងតម្លៃចន្លោះពី១១ ០០០រៀល ទៅ១៣ ០០០ពាន់រៀល។ កម្ពុជាទំនងជាមិនអាចជួបវិបត្តិខ្វះអំបិលសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់របស់ប្រជាពលរដ្ឋដូចឆ្នាំ២០១៨ និងឆ្នាំ២០១៩ ឡើយនៅឆ្នាំនេះ។ កម្ពុជា ធ្លាប់នាំអំបិលយកទៅលក់នៅលើទីផ្សារអន្តរជាតិ ប្រមាណ២០០តោន ម្តងផងដែរ។ បច្ចុប្បន្ននៅខេត្តកំពត និងកែបមានផ្ទៃដីផលិតអំបិលប្រហែល ៤ ៥០០ហិកតា។ ប្រសិនបើអាកាសធាតុអំណោយផលក្នុង១ហិកតា គេអាចផលិតអំបិលបានជាង២០តោន សម្រាប់រយៈពេល១ឆ្នាំ ដោយគិតចាប់ពីខែមករា ដល់ខែឧសភា។ កាលពីឆ្នាំ២០១៨ កន្លងកម្ពុជាបាននាំចូលអំបិលពីចិន ១ម៉ឺនតោន និងនៅឆ្នាំ២០១៩ បាននាំចូលអំបិលពីឥណ្ឌា និងចិនក្នុងរង្វង់៣ម៉ឺនតោន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២។*

## កម្ពុជា រំពឹងរកបានចំណូល៣៥លានដុល្លារពី វិស ័យ បនល្បែង នៅឆ្នា ំ២០២២នេះ



*ដោយ ខេមបូណ្ឌមីស*

ឆ្នាំ២០២២ ជាឆ្នាំដែលត្រូវអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដែលតម្រូវឱ្យស្ថាប័នមានសមត្ថកិច្ចត្រូវស្រង់ស្ថិតិចំនួនកាស៊ីណូ ដែលកំពុងប្រតិបត្តិការនៅទូទាំងប្រទេសឡើងវិញ និងតម្រូវឱ្យម្ចាស់អាជីវកម្មក្នុងវិស័យនេះមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាជាថ្មី។ មកទល់ពេលនេះមានម្ចាស់កាស៊ីណូ

ប្រហែល៨០ហើយបានមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ដើម្បីធ្វើប្រតិបត្តិការដោយស្របច្បាប់។ កាលពីឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបញ្ឈប់ផ្តល់អាជ្ញាបណ្ណល្បែងអនឡាញគ្រប់ប្រភេទនៅកម្ពុជា ហើយ បម្រាមនេះ បានធ្វើឱ្យអាជីវកម្មឧស្សាហកម្មល្បែង និងកាស៊ីណូនៅកម្ពុជាមានការធ្លាក់ចុះយ៉ាងគំហុក ពិសេសនៅក្នុងខេត្តព្រះសីហនុ ដែលមានម្ចាស់កាស៊ីណូ និងអ្នកលេងភាគច្រើនជាជនជាតិចិន។ លុះក្រោយមកទៀត នៅក្នុងឆ្នាំ២០២០ អំឡុងខែមេសា រាជរដ្ឋាភិបាលក៏បានផ្អាកដំណើរការអាជីវកម្មកាស៊ីណូក្រោយមានការរាតត្បាតកូវីដ១៩។ កត្តាទាំងនេះ បានធ្វើឱ្យប្រាក់ចំណូលពន្ធពីវិស័យកាស៊ីណូ នៅឆ្នាំ ២០២០ និង២០២១ មានការថមថយចុះ ពោលគឺក្នុងមួយឆ្នាំមានប្រហែលជាង៩លានដុល្លារអាមេរិកប៉ុណ្ណោះ។

នៅឆ្នាំ២០២២នេះ រដ្ឋបានដាក់គោលដៅប្រមូលចំណូលពីវិស័យនេះឱ្យបានគ្រប់តាមផែនការ ៣៥ លានដុល្លារ។ បច្ចុប្បន្នមានកាស៊ីណូតិចតួចប៉ុណ្ណោះបានបើកប្រតិបត្តិការឡើងវិញ ខណៈកាស៊ីណូជាច្រើនបន្តបិទទ្វារ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

***រូបភាពទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិកាថ្នាក់ជាតិ ក្នុងខែធ្នូ ឆ្នាំ២០២១***




រូបភាពទី១ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែធ្នូ ឆ្នាំ២០២១ ដែលរដ្ឋបាល ថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងប្រទេសសរុបមានចំនួនប្រហែល ២ ៤៣៩ ប៊ីលានរៀល ឬកើន ២៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលមានចំនួនប្រមាណ ១ ៩២៩ ប៊ីលានរៀល។

គិតត្រឹមរយៈពេល ១២ខែ នៃឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ ប្រមូលចំណូលក្នុងប្រទេសសរុប បានសម្រេចតាមផែនការគ្រោងដែលមានចំនួនប្រហែល ២០ ១៣៧ ប៊ីលានរៀល ឬស្មើនឹង ១០១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ខណៈដែលការអនុវត្តក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០ សម្រេចបានត្រឹមតែ ៩០% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។ បើទោះបីជាវិបត្តិជំងឺកូវិដ-១៩ នៅតែបន្តជះឥទ្ធិពលលើសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០២១

នេះ ក៏ដោយ ក៏ការប្រមូលចំណូលក្នុងរយៈពេលពេល ១២ខែ នៃឆ្នាំ២០២១ នៅតែបន្តរក្សាបាននូវនិន្នរភាព និងអនុវត្តបានល្អប្រសើរជាងឆ្នាំ២០២០។

***ដោយ ឈន ហាំ***

*ប្រភព៖ [ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២]*

**រូបភាពទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ខែធ្នូ ឆ្នាំ២០២១**




រូបភាពទី២ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយថវិកា ក្នុងខែធ្នូ ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណាយសរុបថ្នាក់ជាតិមានចំនួនប្រហែល ៣ ៨៥៣ ប៊ីលានរៀល ឬកើន៣០% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ ដែលមានចំនួនប្រហែល ២ ៩៧២ ប៊ីលានរៀល។ កំណើននេះ ដោយសារ នូវតែបន្តចំណាយក្នុងការដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។ ជាក់ស្តែងក្នុងរយៈពេល ១២ខែ នៃឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយលើ អត្ថប្រយោជន៍សង្គម ចំនួន ៣ ៧៨០ ប៊ីលានរៀល ឬស្មើនឹង ១៦៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលកើនឡើង ៥០% ស្របពេលដែលចំណាយលើការទិញ និងសេវាកម្មធ្លាក់ចុះ ២២% និង ៣៣% រៀងគ្នា បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។ គិតត្រឹមរយៈពេល ១២ខែ នៃឆ្នាំ២០២១ ការអនុវត្តចំណាយសរុបថ្នាក់ជាតិ សម្រេចបានចំនួន២៧ ១៧៣ ប៊ីលានរៀល ឬស្មើនឹង៩៣% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១។ ***ដោយ ឈន ហាំ***

*ប្រភព៖ [ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២]*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

**ពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែមករា ឆ្នាំ២០២២ (គិតជាពាន់លានរីងហ្គីត)**

ការនាំចេញទំនិញសរុបរបស់ប្រទេសម៉ាឡេស៊ីមានទំហំ ១១០,៧ ពាន់លានរីងហ្គីត នៅក្នុងខែមករា ឆ្នាំ ២០២២ ពោលគឺ កើនឡើង ២៣,៥% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការកើនឡើងនេះ ដោយមានការគាំទ្រពីការនាំចេញក្នុងស្រុក និងការនាំចេញឡើងវិញ (re-exports)។ ការនាំចេញក្នុងស្រុកមានចំនួនសរុប ៩០,៩ ពាន់លានរីងហ្គីត និងបានរួមចំណែក ៨២,១% នៃការនាំចេញសរុប។ ដូចគ្នាដែរ ការនាំចេញឡើងវិញមានចំនួន ១៩,៨ ពាន់លានរីងហ្គីត ពោលគឺ កើនឡើង ១៣,២% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ ២០២១ ការនាំចេញបានធ្លាក់ចុះ ១០,៦% ឬ ១៣,១ ពាន់លានរីងហ្គីត ប៉ុន្តែការវិភាគលើលក្ខខណ្ឌដែលបានកែតម្រូវតាមរដូវកាលធៀបទៅនឹងខែធ្នូ ឆ្នាំ២០២១

ការនាំចេញបានថយចុះ ៧,៣% ឬ ៨,៦ ពាន់លានរីងហ្គីត។

ចំណែកឯ ការនាំចូលសរុបរបស់ប្រទេសម៉ាឡេស៊ីបានកើនឡើង ២៦,៤% ពី ៧៣ ពាន់លានរីងហ្គីត ទៅ ៩២,៣ ពាន់លានរីងហ្គីត នៅក្នុងខែមករា ឆ្នាំ២០២២។ បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០២១ ការនាំចូលបានថយចុះតិចតួចត្រឹម ០,៦% ឬ៥៣៨,២ លានរីងហ្គីត។

ជារួម ប្រទេសម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ១៨,៤ ពាន់លានរីងហ្គីត កើនឡើង ១០,៩% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕

*ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចេញ | ១១០,៧ |
| ការនាំចូល | ៩២,៣ |
| តុល្យភាពពាណិជ្ជកម្ម | ១៨, ៤ |

*ប្រភព៖ Department of Statistics Malaysia Official Portal*

## ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេងរបស់សិង្ហបុរីទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែមករា ឆ្នាំ ២០២២

តារាងខាងក្រោមបង្ហាញពី ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX: (Non-oil domestic exports)) ទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែមករា ឆ្នាំ២០២២។

NODX ទៅកាន់អាមេរិចបានកើនឡើង ៤៥,៥% នៅក្នុងខែមករា ឆ្នាំ២០២២ ខណៈ NODX កាលពីខែធ្នូ ឆ្នាំ២០២១ បានថយចុះ ២៥,៦%។ ការកើនឡើងនេះជំរុញដោយកំណើនគ្រោងឆ្អឹងនៃកប៉ាល់ និងទូក (Structures of ships and boats) និងគ្រឿងចក្រឯកទេសមានចំនួន ១៨៧,៥% និងឧបករណ៍វាស់ស្ទង់មានចំនួន ៤៣,២%។

NODX ទៅកាន់ចិនបានកើនឡើង ២៦,១% នៅក្នុងខែមករា ឆ្នាំ២០២២ បន្ទាប់ពីមានកំណើន ៣៦,៣% កាលពីខែធ្នូ ឆ្នាំ២០២១។ កំណើននេះរួមចំណែកដោយគ្រឿងចក្រឯកទេសមានចំនួន ៥៨,៦% មិនមែនរូបិយវត្ថុមាស (non-monetary gold) និងគីមីឥន្ធនៈ (petrochemicals) មានចំនួន ១៥,៤%។

NODX ទៅកាន់សហគមន៍អឺរ៉ុបបានកើនឡើង ៣២,២% នៅក្នុងខែមករា ឆ្នាំ២០២២ បន្ទាប់ពីមានកំណើន ៣២,៥% កាលពីខែធ្នូ ឆ្នាំ២០២១។ ការកើនឡើងនេះដោយសារការនាំចេញគ្រឿងបរិក្ខារវិស្វកម្មសំណង់ស៊ីវិល និងគ្រឿងចក្រឯកទេសមានចំនួន ៦៧% និងឱសថមានចំនួន ១៧%។

ជារួម NODX ទៅកាន់ទីផ្សារធំៗទាំង១០ បានកើនឡើងនៅក្នុងខែមករា ឆ្នាំ២០២២ ទោះបីជា NODX ទៅទីផ្សារថៃ និងហុងកុង និងកូរ៉េខាងត្បូងបានធ្លាក់ចុះក៏ដោយ។ ទីផ្សារធំបំផុត នៃNODX របស់ប្រទេសសង្ហបុរីគឺអាមេរិចមាន ៤៥,៥% ចិនមាន ២៦,១% និងសហគមន៍អឺរ៉ុបមាន ៣២,២%៕ *ដោយ ជឹម ប៊ុនធឿន*

| ទីផ្សារធំៗ | កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (%) | |
|---|---|---|
| | ធ្នូ ឆ្នាំ២០២១ | មករា ឆ្នាំ ២០២២ |
| **អាមេរិក** | -២៥,៦ | ៤៥,៥ |
| **ចិន** | ៣៦,៣ | ២៦,១ |
| **សហគមន៍អឺរ៉ុប** | ៣២,៥ | ៣២,២ |
| **ម៉ាឡេស៊ី** | ១៣ | ២០,១ |
| **ឥណ្ឌូនេស៊ី** | ៦៦,១ | ២៩,៦ |
| **តៃវ៉ាន់** | ១៦,៥ | ១៣,១ |
| **ជប៉ុន** | ១៥,៥ | ៩,៣ |

| | | |
|---|---|---|
| **កូរ៉េខាងត្បូង** | -១៦,៤ | -២,៧ |
| **ហុងកុង** | ៩,២ | -៥,៦ |
| **ថៃ** | ២៨,៧ | -២៣ |

*ប្រភព៖www.enterprisesg.gov.sg*

## អតិរេកពាណិជ្ជកម្មនៅខែកុម្ភៈរបស់ប្រទេសឥណ្ឌូណេស៊ីដោយសារការពង្រីកលើការនាំចេញទំនិញដ៏ខ្លាំងក្លា



*ប្រភព៖ CNA, រូបភាព៖ Willy Kurniawan*

កំណើនការនាំចេញរបស់ឥណ្ឌូនេស៊ី ទំនងជាកើនឡើងក្នុងខែកុម្ភៈ ដោយសារតម្លៃទំនិញខ្ពស់ ខណៈដែលជម្លោះរវាងអ៊ុយក្រែន និងរុស្ស៊ីបានជំរុញឱ្យមានការព្រួយបារម្ភអំពីការធ្លាក់ចុះនៃការផ្គត់ផ្គង់ និងនៅពេលដែលអាជ្ញាធរនៅទីក្រុងហ្សាការតា បានលុបចោលការហាមឃាត់លើការនាំចេញធ្យូងថ្ម។

អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាស៊ីអាគ្នេយ៍ ត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ១.៦៦ប៊ីលានដុល្លារ ក្នុងខែកុម្ភៈ កើនឡើងពីប្រហែល ៩៣០លានដុល្លារ ក្នុងខែមករា ខណៈប្រទេសដែលសម្បូរធនធាន បាននឹងកំពុងរីករាយនឹងការកើនឡើងនៃការនាំចេញ ដែលនៅពីលើការកើនឡើងនៃតម្លៃទំនិញ ដែលអនុញ្ញាតឱ្យប្រទេសនេះកត់ត្រាអតិរេកពាណិជ្ជកម្មជារៀងរាល់ខែចាប់តាំងពីខែឧសភា ឆ្នាំ ២០២០។

ការនាំចេញនៅខែកុម្ភៈ ត្រូវបានគេព្យាករណ៍ថានឹងបង្ហាញពីការកើនឡើង ៣៧.៣២% ប្រចាំឆ្នាំ កើនពី ២៥.៣១%នាខែមករា ខណៈដែលការនាំចូលខែកុម្ភៈ ត្រូវបានគេមើលឃើញថាកើនឡើង ៤០.០៤%ធៀបនឹង ៣៦.៧៧% កាលពីខែមុន។ ហើយក្រុមអ្នកវិភាគ ANZ ដែលបានព្យាករណ៍ពីអតិរេកពាណិជ្ជកម្មចំនួន ២.៦៥ប៊ីលានលានដុល្លារសម្រាប់ខែកុម្ភៈ បាននិយាយថា ការនាំចេញ បានទទួលការជំរុញពីការលុបចោលការហាមឃាត់ការនាំចេញធ្យូងថ្ម ក៏ដូចជាតម្លៃទំនិញឡើងថ្លៃ ដូចជាធ្យូងថ្ម និងប្រេងដូងជាដើម។

ឥណ្ឌូណេស៊ី ដែលជាប្រទេសនាំចេញធ្យូងថ្មដ៏ធំបំផុតរបស់ពិភពលោក បានបញ្ឈប់ការនាំចេញឥន្ធនៈសម្រាប់ផ្នែកនៃខែមករា ដោយសារកម្រិតស្តុកទាបនៅរោងចក្រថាមពលក្នុងស្រុកក្នុងការផ្លាស់ប្តូរ ដែលបានលុបចោលការនាំចេញឥន្ធនៈរ៉ែចំនួន ២ប៊ីលានដុល្លារ។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNA ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០២២*

## អត្រាអ្នកអត់ការងារធ្វើធ្លាក់ចុះដល់កម្រិតមុនជំងឺរាតត្បាត ការស្ទុះងើបឡើងវិញនៃទីផ្សារការងារនឹងបន្តឆ្នាំ 2022



*ប្រភព៖ CNA, រូបភាព៖ Gaya Chandramohan*

ការងារសរុប បានស្ទុះងើបឡើងវិញនៅឆ្នាំ២០២១ ជាមួយ នឹងអត្រាអ្នកអត់ការងារធ្វើធ្លាក់ចុះដល់កម្រិតមុនពេលការរាតត្បាតជំងឺកូវីដ១៩ យោងតាមរបាយការណ៍ទីផ្សារការងារឆ្នាំ២០២១ របស់ក្រសួងធនធានមនុស្សសិង្ហបុរី (MOM)។

ការស្ទុះងើបឡើងវិញនៃទីផ្សារការងារ ត្រូវបានគេរំពឹងថានឹងបន្តនៅឆ្នាំនេះ ជាមួយនឹងកំណើនសេដ្ឋកិច្ចកើនឡើង។

អត្រាអ្នកអត់ការងារធ្វើជាមធ្យមប្រចាំឆ្នាំ បានធ្លាក់ចុះពី ៣%ទៅ២.៧% ដោយអត្រាអ្នកអត់ការងារធ្វើរបស់និវាសនជន បានធ្លាក់ចុះពី ៤.១%ទៅ៣.៥% ខណៈដែលអត្រាអត់ការងារធ្វើរបស់ពលរដ្ឋគឺ ៣.៧% ធ្លាក់ចុះពី ៤.២% ហើយក្នុងខែមករា ឆ្នាំ២០២២ អត្រាអ្នកគ្មានការងារធ្វើបានធ្លាក់ចុះដល់កម្រិតនៅ ខែធ្នូ ឆ្នាំ ២០១៩ ។ ចំនួនការងារសរុប បានស្ទុះងើបឡើងវិញនៅឆ្នាំ២០២១ កើនឡើង ៤១ ៤០០កន្លែង បន្ទាប់ពីការធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០២០ នៅពេលដែលការងារ១៦៦ ៦០០ កន្លែង ត្រូវបានបាត់បង់។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNA ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២*

## តើប្រទេសសមាជិកអាស៊ានមួយណា ដែលនាំចូលអង្ករពីកម្ពុជាច្រើនជាងគេ?




*ដោយ ខេមបូណ្ឌមីស*

ក្រៅតែពីទីផ្សារចិន និងអឺរ៉ុប កម្ពុជាកំពុងជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញអង្កររបស់ខ្លួនកាន់តែខ្លាំង។ ទីផ្សារអាស៊ានក៏ជាគោលដៅនាំចេញអង្ករធំមួយដែររបស់កម្ពុជា។ ប្រទេសម៉ាឡេស៊ី គឺជាទីផ្សារធំជាងគេនៅក្នុងតំបន់អាស៊ានដែលនាំចូលអង្ករកម្ពុជា ច្រើនជាងគេបន្ទាប់ពីប្រទេសចិនដែលឈរក្នុងលំដាប់លេខ១ និងប្រទេសបារាំងឈរនៅលំដាប់លេខ២។ ការដឹកជញ្ជូនអង្ករទៅកាន់ប្រទេសម៉ាឡេស៊ី មានភាពងាយស្រួល និងស្ថិតនៅជិតប្រទេសកម្ពុជាផងនោះ។ ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ អង្ករកម្ពុជា ដែលបាននាំចេញទៅកាន់ទីផ្សារម៉ាឡេស៊ី មានបរិមាណសរុប ជាង២០ម៉ឺនតោន ឬស្មើជិត ៧% នៃបរិមាណនាំចេញសរុប ៣លានតោន។ ដោយឡែក នៅក្នុងឆ្នាំ២០២១ កម្ពុជាបានធ្វើការនាំចេញអង្ករក្រអូប ទៅម៉ាឡេស៊ី បានប្រមាណ ៤ម៉ឺន៦ពាន់តោន។

អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា បានគូសបញ្ជាក់ដូច្នេះ បច្ចុប្បន្ន អង្ករកម្ពុជា ហាក់កាន់តែមានទីផ្សារសម្រាប់ប្រជាជនម៉ាឡេស៊ី ខណៈប្រទេសវៀតណាមវិញ គឺជាទីផ្សារធំដែរសម្រាប់ការនាំចេញស្រូវរបស់កម្ពុជា។ តម្លៃនាំចេញអង្ករ ទៅកាន់ទីផ្សារនៅតំបន់អាស៊ាន និងអឺរ៉ុប រួមទាំងប្រទេសចិន សុទ្ធតែមានតម្លៃដូចគ្នា ក៏ប៉ុន្តែខុសគ្នានៅត្រង់តម្លៃដឹកជញ្ជូន។ នៅក្នុងប្រទេសម៉ាឡេស៊ី ប្រជាជនដែលមានវ័យចំណាស់ភាគច្រើនបានស្គាល់កេរ្តិ៍ឈ្មោះអង្ករក្រអូបកម្ពុជា តាំងពីសម័យមុនសង្គ្រាម ដែលកម្ពុជាធ្លាប់បាននាំចេញទៅលក់នៅទីនោះ ខណៈនៅសម័យកាលនោះអង្ករក្រអូបកម្ពុជាពូជស្រូវឈ្មោះ «សូម៉ាលី» ដែលបច្ចុប្បន្ន អង្ករដែលវេចខ្ចប់ ដោយដាក់ឈ្មោះ«សូម៉ាលី» គឺនៅតែបន្តពេញនិយមនៅក្នុងទីផ្សារ ប្រទេសម៉ាឡេស៊ី។

សូមបញ្ជាក់ថា នៅឆ្នាំ២០២១ កម្ពុជា បាននាំចេញអង្ករជាង៦១ម៉ឺនតោន ទៅកាន់ទីផ្សារអន្តរជាតិ។ ដោយឡែក រយៈពេល ២ខែដំបូងក្នុងឆ្នាំ២០២២នេះ កម្ពុជាបាននាំចេញអង្ករ ជាង១០ម៉ឺនតោន។ គោលដៅនាំចេញអង្ករសំខាន់ៗ របស់កម្ពុជា មានដូចជា ទីផ្សារអឺរ៉ុប ប្រទេសចិន និងតំបន់អាស៊ាន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។*

## រដ្ឋាភិបាលវៀតណាមស្វែងរកការអនុម័តពីសភា ដើម្បីកាត់បន្ថយពន្ធលើប្រេងសាំងដែលកំពុងកើនខ្ពស់



*ដោយ ខេមបូណ្ឌមីស*

គិតតាំងពីខែធ្នូចុងឆ្នាំ២០២១ មកដល់ជិតពាក់កណ្តាលខែមីនានេះ តម្លៃប្រេងសាំងនៅវៀតណាមបានកើនឡើងជាង៣០% ដែលមានតម្លៃខ្ពស់បំផុតមិនធ្លាប់មាន ពោលគឺជិត ៣ម៉ឺនដុងក្នុងមួយលីត្រ ឬស្មើនឹងប្រហែល៥ពាន់៣រយរៀលក្នុងមួយលីត្រ។

ក្រសួងហិរញ្ញវត្ថុវៀតណាម បានដាក់សំណើមួយទៅកាន់រដ្ឋាភិបាលដើម្បីជំរុញឱ្យសភាសម្រេចអនុម័ត លើការកាត់បន្ថយពន្ធពាក់កណ្តាលនៃពន្ធបរិស្ថានលើតម្លៃប្រេងសាំង។ ពន្ធប្រភេទនេះមានតម្លៃប្រមាណ ១៧ សេន ក្នុងសាំងមួយលីត្រ។ សភាជាតិវៀតណាម នឹងធ្វើការពិនិត្យឡើងវិញចំពោះ ពន្ធលើប្រេងសាំងនេះ ហើយប្រសិនបើសភាពអនុម័តឱ្យមានការកាត់បន្ថយពន្ធនេះមែននោះ វានឹងចូលជាធរមានចាប់ពីថ្ងៃទី ១ ខែមេសាខាងមុខនេះតទៅ។ ការកាត់បន្ថយពន្ធនេះនឹងជួយឱ្យតម្លៃប្រេងសាំងនាពេលបច្ចុប្បន្នដែលមាន ប្រហែល ៥ពាន់៣ររៀលក្នុងមួយលីត្រនោះ នឹងអាចថយចុះ ប្រមាណ ៧,៤% ឬថយចុះតម្លៃជិត៤០០ រៀលក្នុងមួយលីត្រ។

តម្លៃប្រេងសាំងនៅវៀតណាម បច្ចុប្បន្នគឺមានរួមបញ្ចូលនូវតម្លៃពន្ធក្នុងនោះ ប្រហែល៤០% រួមមានដូចជាពន្ធលើការប្រើប្រាស់ពិសេស, ពន្ធនាំចូល, ពន្ធអាករលើតម្លៃបន្ថែម (VAT), និងពន្ធបរិស្ថាន និងការចំណាយនានាជាដើម។

បើធៀបនឹងប្រទេសតំបន់អាស៊ីអាគ្នេយ៍តម្លៃប្រេងសាំងនៅក្នុងប្រទេសវៀតណាម គឺមានថ្លៃជាងប្រេងសាំងនៅកម្ពុជា, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងហ្វីលីពីនទៅទៀត។ ផែនការកាត់បន្ថយពន្ធលើប្រេងសាំងក៏ដូចជាប្រេងម៉ាស៊ូត និងប្រេងរំអិលផ្សេងៗទៀតរបស់វៀតណាមនេះ ត្រូវបានគេរំពឹងថា នឹងអាចធ្វើឱ្យរដ្ឋាភិបាលនឹងត្រូវបាត់បង់ចំណូលប្រហែលជិត១ពាន់៣រយលានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០២២។ *ដោយ ម៉ែន ខេមរៈ*
*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

### ការស្ទង់មតិរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិកបង្ហាញថាអ្នកប្រើប្រាស់បានព្យាករណ៍ថាអតិផរណាមានការងើបឡើងទៅលើការចំណាយផ្សេងៗ



*ប្រភព៖ Reuter, 2020 រូបភាព៖ Jason Redmond*

ការព្យាករពីអត្រាអតិផរណានៅក្នុងឆ្នាំនេះ បានកើនឡើងដល់៥,៨%ក្នុងខែមករា នឹងបន្តកើន ឡើងដល់ ៦% ក្នុងខែកុម្ភៈដែលនេះជាអត្រាមួយដែលត្រឡប់ទៅកម្រិត ខ្ពស់ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៣។

គ្រួសារនៅសហរដ្ឋអាមេរិកកំពុងប្រឈមមុខនឹងការកើនឡើងតម្លៃទំនិញលឿនបំផុតដែលពុំធ្លាប់មាន ដូចនេះ

ស្របពេលជាមួយគ្នានេះ ការលុកលុយរបស់រុស្ស៊ីលើអ៊ុយក្រែន ក៏ជាចំណែកមួយ ដែលនាំឱ្យតម្លៃប្រេងឥន្ធនៈឡើងថ្លៃ និងអាចនាំឱ្យមានការកើនឡើងថ្លៃម្ហូបអាហារ ។ រង្វាស់នៃការព្យាករណ៍អតិផរណារបស់សហរដ្ឋអាមេរិក ផ្អែកលើទីផ្សារដោយ ICE Benchmark ( IBA ) ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ បានបង្ហាញថាការព្យាករណ៍រយៈពេលខ្លីបានបញ្ជាក់ពីការងើបយ៉ាងខ្លាំងនៃអត្រាអតិផរណា ព្រមទាំងបាន ឆ្លើយតបទៅនឹងទិន្នន័យរបស់រដ្ឋាភិបាលដែលបង្ហាញពីអតិផរណាដែលកំពុងដំណើរការប្រហែល៧% ហើយបានកើនឡើងម្តងទៀតបន្ទាប់ពីការវាយប្រហាររបស់រុស្ស៊ី។

មន្ត្រីជំនាញរបស់ Fed ត្រៀមចាត់វិធានការដ៏សំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងនឹងអតិផរណាតាមរយៈការដំឡើងអត្រាការប្រាក់ បន្ទាប់ពីបានកាត់បន្ថយអត្រាការប្រាក់ក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតរាតត្បាត។

ស្ថានភាពសេដ្ឋកិច្ចអាមេរិកកំពុងស្ថិតនៅលើស្ថិរភាពកាន់តែខ្លាំងនៅពេលនេះ ដោយមានអត្រាគ្មានការងារធ្វើនៅកម្រិត ៣,៨%% និងប្រាក់ឈ្នួលកើនឡើងប៉ុន្តែគ្រួសារជាច្រើនក៏ជួបការលំបាកជាមួយនឹងការឡើងថ្លៃ ទំនិញផងដែរ។

គិតត្រឹមខែកុម្ភៈ អ្នកប្រើប្រាស់បានបញ្ជាក់ថា៖ ពួកគេរំពឹងថាការចំណាយរបស់ពួកគេនឹងកើនឡើង ៦,៤% កើនឡើងយ៉ាងខ្លាំងពី ៥,៥% ដែលរំពឹងទុកក្នុងខែមករាសម្រាប់មួយឆ្នាំ និងអាចឈានដល់កម្រិតខ្ពស់ថ្មីមួយទៀត។ សម្រាប់ តម្លៃម្ហូបអាហារនឹងកើនឡើង ៩,២% ក្នុងមួយឆ្នាំ កើនឡើងពីការរំពឹងទុក ៥,៩%% ក្នុងខែមករា ហើយតម្លៃឧស្ម័ននឹងកើនឡើង ៨,៨% កើនឡើងពីការប៉ាន់ប្រមាណពីមុន៧,៣%៕ *ដោយ សេន ចន្ទី*

*ប្រភព៖ usnews,ចេញផ្សាយ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២*

## តំបន់ដែលប្រើប្រាស់ប្រាក់អឺរ៉ូបានរឹតបន្តឹងគោលនយោបាយ សារពើពន្ធនៅឆ្នាំ២០២៣ដើម្បីត្រៀមខ្លួនជាស្រេចក្នុងការបញ្ច្រាសសង្គ្រាមអ៊ុយក្រែន



*ប្រភព៖ Reuters, 2022 រូបភាព៖ Yves Herman*

រដ្ឋមន្ត្រីនៃក្រសួងហិរញ្ញវត្ថុប្រចាំតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូបានយល់ព្រមលើការរឹតបន្តឹងគោលនយោបាយសារពើពន្ធនៅឆ្នាំក្រោយ បន្ទាប់ពី បីឆ្នាំនៃការចំណាយប្រាក់រាប់ពាន់លានដើម្បីស្តារសេដ្ឋកិច្ចដោយសារជំងឺរាតត្បាតកូវីដ-១៩ ប៉ុន្តែក៏ត្រូវត្រៀមខ្លួនជាមួយនឹងសាច់ប្រាក់បន្ថែមទៀតប្រសិនបើសង្គ្រាមនៅអ៊ុយក្រែនធ្វើឱ្យប៉ះពាល់ខ្លាំងដល់តំបន់ទាំងនេះ។

រដ្ឋមន្ត្រីមកពីប្រទេសចំនួន ១៩ ដែលប្រើប្រាស់ប្រាក់អឺរ៉ូបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយបន្ទាប់ពីកិច្ចពិភាក្សាជាទៀងទាត់ថា "មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូមានភាពរឹងមាំ"។ប៉ុន្តែភាពមិនច្បាស់លាស់ ក៏បានកើតឡើងផងដែរដោយសារ ផលប៉ះពាល់សេដ្ឋកិច្ច ដែលបណ្តាលមកពីសង្គ្រាមរបស់រុស្ស៊ីនឹងអ៊ុយក្រែន មិនទាន់ត្រូវបានកំណត់ និងបន្ថែមហានិភ័យដល់បញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់ តម្លៃថាមពលខ្ពស់ និង អតិផរណាក្នុងរយៈពេលយូរ ដែលអាចខ្ពស់ជាងការរំពឹងទុក។

ទន្ទឹមនឹងនេះ គណៈកម្មាការដែលជានាយកប្រតិបត្តិរបស់សហភាពអឺរ៉ុបបានផ្តល់អនុសាសន៍ ថារដ្ឋាភិបាលសហភាពអឺរ៉ុបគួរតែផ្លាស់ប្តូរនូវជំហរសារពើពន្ធអព្យាក្រឹតនៅឆ្នាំក្រោយពីជំហរគាំទ្រនៅពេលនេះ ដោយសារសេដ្ឋកិច្ច

កំពុងរីកចម្រើន ហើយបណ្តាប្រទេសសហភាពអឺរ៉ុបមានបំណុលធំដោយសារជំងឺរាតត្បាត។ លើសពីនេះរដ្ឋាភិបាលគួរតែត្រៀមខ្លួនជាស្រេចដើម្បីផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅគាំទ្រសេដ្ឋកិច្ចជាមួយនឹងសាច់ប្រាក់សាធារណៈដែលជាបញ្ហាប្រឈមនៃការឈ្លានពានរបស់រុស្ស៊ី លើអ៊ុយក្រែននាំមក។

ការផ្លាស់ប្តូរគោលនយោបាយរហ័សដែលមានសក្តានុពលនឹងត្រូវបានធ្វើឱ្យកាន់តែងាយស្រួល ហើយដែនកំណត់នៃការខ្ចីប្រាក់របស់រដ្ឋាភិបាលសហភាពអឺរ៉ុប ដែលត្រូវបានផ្អាកជាលើកដំបូងក្នុងឆ្នាំ ២០២០ ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតទំនងជានឹងបន្តផ្អាក នៅឆ្នាំ២០២៣ ដោយសារតែភាពមិនច្បាស់លាស់ដែល នាំមកដោយសង្គ្រាម។ ទោះយ៉ាងណាក៏ដោយ រដ្ឋមន្ត្រីបានយល់ស្របថា ប្រទេសដែលមានបំណុលខ្ពស់ដូចជាអ៊ីតាលី ឬក្រិចគួរតែផ្តោតលើការកាត់បំណុល ខណៈដែលប្រទេសដែលមានបំណុលទាបផ្តោតលើការវិនិយោគកាន់តែច្រើន។ ធនាគារកណ្តាលអ៊ឺរ៉ុបបានព្យាករណ៍ ថាកំណើនតំបន់ចាយប្រាក់អឺរ៉ូនឹងមាន ០,៥ពិន្ទុគោល នៅឆ្នាំ នេះយឺតជាងការរំពឹងទុកពីមុន ដោយសារសង្គ្រាមនៅអ៊ុយក្រែន ប៉ុន្តែនៅតែរក្សាក្នុងកម្រិត ៣,៧% និង ២,៨% នៅឆ្នាំ ២០២៣។

សម្រាប់ការព្យាករណ៍របស់ធនាគារកណ្តាលអឺរ៉ុប (ECB), អតិផរណាត្រូវបានកំណត់ជាមធ្យម ៥,១% ក្នុងឆ្នាំ ២០២២ ដែលលើសពីគោលដៅ ២% និងធ្លាក់ចុះមក ២,១% ក្នុងឆ្នាំ ២០២៣ ។

*ដោយ **សេន ចន្ទី***

*ប្រភព៖ usnews,ចេញផ្សាយ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២*

## រដ្ឋជាច្រើននៅអាមេរិកអំពាវនាវឱ្យផ្អាកយកពន្ធឧស្ម័ន ស្របពេលដែលតម្លៃឧស្ម័នកំពុងកើនខ្លាំង




*ដោយ ខេមបុណ្ណមីស*

ស្របពេលដែលតម្លៃឧស្ម័នកើនឡើងក្នុងកម្រិតខ្ពស់បំផុតនៅទូទាំងសហរដ្ឋអាមេរិក អភិបាលក្រុង និង សមាជិកសភារដ្ឋ កាន់តែច្រើនឡើងអំពាវនាវឱ្យផ្អាកការយកពន្ធហ្គាស ដើម្បីសម្រួលដល់អ្នកបើកបរដែលកំពុងប្រឈមមុខនឹងការកើនឡើងតម្លៃឧស្ម័នកាន់តែខ្ពស់។ រដ្ឋាភិបាលអាមេរិកបានយកពន្ធជាង ១៨សេនក្នុងហ្គាសមួយហ្គាឡុង ឬស្មើនឹងជិត៤លីត្រ។ សំណើសម្រាប់ លើកលែងពន្ធឧស្ម័ន ដើម្បីទប់ទល់នឹងអតិផរណា បាននិងកំពុងដំណើរការបន្តិចម្តងៗនៅក្នុងសភា និងតាមរដ្ឋធានី តាំងតែមុនពេលរុស្ស៊ីឈ្លានពានអ៊ុយក្រែនទៅទៀត ប៉ុន្តែដោយសារតម្លៃឧស្ម័នហាក់កើនឡើងកាន់តែខ្ពស់នៅក្នុងសប្តាហ៍នេះ ដូចនេះហើយ ទើបអភិបាលក្រុងនីមួយៗនៅសហរដ្ឋអាមេរិកកំពុងជំរុញពន្លឿនសំណើផ្អាកយកពន្ធហ្គាសនេះ។ ថ្នាក់ដឹកនាំមកពីគណបក្សសាធារណរដ្ឋនៅក្នុងរដ្ឋ Michigan និង Pennsylvania អភិបាលរដ្ឋ Georgia មកគណបក្សសាធារណរដ្ឋ អភិបាលរដ្ឋកាលីហ្វ័រញ៉ាមកពីគណបក្សប្រជាធិបតេយ្យ និង អភិបាលរដ្ឋផ្សេងៗទៀត បានអំពាវនាវឱ្យមានការបន្ធូរបន្ថយពន្ធឧស្ម័នរដ្ឋដូចគ្នាផងដែរនេះ រហូតដល់ចុងឆ្នាំ២០២២។ ជាពិសេសនៅពេលដែលប្រធានាធិបតីសហរដ្ឋអាមេរិក

បានបញ្ហាឱ្យកាត់ផ្តាច់សរសៃឈាមសេដ្ឋកិច្ចរុស្ស៊ី ដោយហាមឃាត់ការនាំចូលប្រេងពីរុស្ស៊ី។ តែយ៉ាងណាមិញ ក៏មានអ្នករិះគន់លើសំណើនេះដែរ ដោយលើកឡើងថា វាមិនមានការធានាថាការសន្សំប្រាក់ពីការកាត់បន្ថយពន្ធឧស្ម័ននឹងទៅដល់អ្នកប្រើប្រាស់នោះទេ ហើយគេបារម្ភថាការផ្អាកការយកពន្ធឧស្ម័នអាចប៉ះពាល់ដល់មូលនិធិសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធផ្លូវថ្នល់ផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។*

## ចិនបានក្លាយជាប្រទេសឈានមុខគេ លើពិភពលោកក្នុងការនាំចេញ រថយន្តអគ្គីសនី




*ដោយ freshnews*

ប្រទេសចិនជាទីផ្សារដ៏ធំបំផុតមួយដែលបាននាំចេញរថយន្តអគ្គីសនីបានជិត ៥០០ ០០០ គ្រឿងនៅក្នុងឆ្នាំ២០២១ ដែលវាគឺជាចំនួនដ៏ច្រើនបើធៀបទៅនឹងប្រទេសផ្សេងទៀតនៅក្នុងពិភពលោក លក់នៅប៉ែកអ៊ឺរ៉ុប និងអាស៊ីអាគ្នេយ៍។ ចំនួនរថយន្តអគ្គីសនីដឹកអ្នកដំណើរដែលបាននាំចេញនោះ បានកើនឡើង ២.៦ដង ដែលមានចំនួនរហូតដល់ទៅ ៤៩៩ ៥៧៣ គ្រឿង។ ការនាំទៅអ៊ឺរ៉ុបបានកើនឡើង ៥ដង និងមានចំនួន ២៣០ ០០០គ្រឿង បានស្រូបយកពាក់កណ្តាលនៃការនាំចេញរថយន្តអគ្គីសនីសរុបរបស់ប្រទេសចិន។ ប្រទេសចិនមានចំណែក៦០%នៃផលិតកម្មរថយន្តអគ្គីសនីទូទាំងពិភពលោក ហើយក៏កំពុងក្លាយជារោងចក្រគោលដៅរបស់ពិភពលោកផងដែរ។ ផលិតកម្មនៅប្រទេសចិនបានកើនឡើង ៥៧,៤% នៃចំនួនសរុប ហើយអ៊ឺរ៉ុប និងសហរដ្ឋអាមេរិកមានចំនួន២២% និង ១២%រៀងគ្នាហើយជប៉ុនមានត្រឹមតែ0,៩%ប៉ុណ្ណោះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។*

## បារាំងចង់ឱ្យសហភាពអឺរ៉ុបកំណត់កញ្ចប់បំណុលថ្មី ចំពេលសង្គ្រាមនៅអ៊ុយក្រែនតានតឹងខ្លាំង



*ដោយ ខេមបូណ្ឌមីស*

ប្រទេសមួយចំនួននៃរដ្ឋសមាជិកសហភាពអឺរ៉ុប ដូចជាបារាំង និងអ៊ីតាលី ចង់បានបំណុលថ្មី ដែលចេញរួមគ្នាដោយសហភាពអឺរ៉ុប ដើម្បីយកមកជួយកាត់បន្ថយការប៉ះពាល់ បន្ទាប់ពីខ្លួនសម្រេចកែប្រែការទិញយកថាមពលរបស់រុស្ស៊ីមួយចំនួន ផលប៉ះពាល់នៃទណ្ឌកម្មដែលដាក់លើទីក្រុងម៉ូស្គូ និងជំរុញឱ្យមានឯករាជ្យភាពបន្ថែមទៀតលើការផ្គត់ផ្គង់ស្បៀងអាហារ និងបន្ទះមីក្រូឈីប។ ប៉ុន្តែប្រទេសអាល្លឺម៉ង់ ហូឡង់ និងរដ្ឋជាសមាជិកមួយចំនួនផ្សេងទៀតជំទាស់យ៉ាងខ្លាំង ដោយអះអាងថា ប្រាក់ប្រមាណ ៨០០ពាន់លានអឺរ៉ូ ដែលអឺរ៉ុបបានខ្ចីរួមគ្នាកាលពីមួយរយៈមុនសម្រាប់ប្រើជាមូលនិធិសង្គ្រោះអំឡុងជំងឺរាតត្បាតកូវីដ១៩ នៅមិនទាន់បានប្រើប្រាស់អស់ផង ហេតុនេះ គេមិនអាចបង្កើនកំរិតបំណុលថ្មី និងខ្ចីបន្ថែមបាននៅឡើយទេ។

យ៉ាងណាក៏ដោយ ប្រធានាធិបតីបារាំង នៅតែមានជំនឿចិត្តថា មេដឹកនាំអឺរ៉ុបទាំងអស់នឹងយល់ស្របជាមួយនឹងគំនិតរបស់លោក។ ព្រោះសហភាពអឺរ៉ុបធ្លាប់បានសម្រេចចិត្តខ្ចីប្រាក់ប្រមាណ ៨០០ពាន់លានដុល្លារ នាឆ្នាំ២០២០ សម្រាប់ការស្តារឡើងវិញ និងដោះស្រាយកូវីដ១៩ ។

ដោយសារតែសង្គ្រាមនៅអ៊ុយក្រែនត្រូវបានគេប្រមើលឃើញថា នឹងមិនងាយដោះស្រាយចប់ សហភាពអឺរ៉ុបដើរតួនាទីសំខាន់ណាស់ ដើម្បីចាត់វិធានការ និងគោលនយោបាយនានា ទប់ទល់នឹងឥទ្ធិពលនៃសង្គ្រាម ដែលកំពុងសាយភាយមកលើវិស័យសំខាន់ជាច្រើននៅក្នុងតំបន់ និងពិភពលោក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។*

## ឥណ្ឌាត្រៀមខ្លួនជាស្រេចដើម្បីបំពេញកង្វះខាតស្រូវសាលីដែលបង្កដោយសង្គ្រាមរវាងអ៊ុយក្រែន និងរុស្ស៊ី



*ដោយ rasmeinews*

ប្រទេសរុស្ស៊ី និងអ៊ុយក្រែនមានចំណែក ២៩%នៃការនាំចេញស្រូវសាលីជាសកល ប៉ុន្តែដោយសារជម្លោះរវាងពួកគេកាន់តែតានតឹងឡើង ការផ្គត់ផ្គង់អាចនឹងត្រូវធ្លាក់លើឥណ្ឌា ដែលជាប្រទេសផលិតស្រូវសាលីធំទីពីររបស់ពិភពលោក។ ប្រទេសមួយចំនួនធំដែលនាំចូលស្រូវសាលីដូចជា ហ្វីលីពីន អេហ្ស៊ីប ម៉ារ៉ុក និងលីបង់ កំពុងស្វែងរកការជំនួសការនាំចេញរបស់រុស្ស៊ី និងអ៊ុយក្រែន ព្រោះឥឡូវនេះការផ្គត់ផ្គង់ស្រូវសាលី ត្រូវបានជាប់គាំងនៅក្នុងប្រទេសអ៊ុយក្រែន ហើយការដាក់ទណ្ឌកម្មបានធ្វើឱ្យប្រទេសនានាពិបាកទិញពីរុស្ស៊ី។

អង្គការស្បៀងអាហារនិងកសិកម្មបានរកឃើញថា នៅឆ្នាំ២០២០ ប្រទេសលីបង់បានប្រើប្រាស់ស្រូវសាលីនាំចូលពីអ៊ុយក្រែន ៨១% និង ១៥%ពីរុស្ស៊ី។ អេហ្ស៊ីបបានទិញស្រូវសាលី ៦០%ពីរុស្ស៊ី និង២៥%ពីអ៊ុយក្រែន។ ហើយប្រហែល ៦៦%នៃការនាំចូលស្រូវសាលីរបស់តួកគី គឺបានមកពីប្រទេសរុស្ស៊ី និង១០%ពីអ៊ុយក្រែន។

រដ្ឋមន្ត្រីស្បៀងអាហារឥណ្ឌា បាននិយាយថា ការនាំចេញស្រូវសាលីសរុបពីប្រទេសឥណ្ឌាបានកើនឡើងដល់ ៦,៦ លានតោនចាប់តាំងពីខែតុលា។

ឥណ្ឌាផលិតស្រូវសាលីប្រហែល ១០៨ លានតោនក្នុងមួយឆ្នាំ ដែលសឹងតែស្មើ ១៤%នៃទិន្នផលសរុបនៅក្រៅប្រទេស ប៉ុន្តែភាគច្រើននៃស្រូវសាលីទាំងនេះត្រូវបានប្រើប្រាស់តែក្នុងស្រុកប៉ុណ្ណោះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ rasmeinews ចេញផ្សាយថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២។*

## អូស្ត្រាលី និងឥណ្ឌាកំពុងឆ្ពោះទៅរកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីកាត់បន្ថយការពឹងផ្អែកលើចិន



*ដោយ ខេមបូណ្ឌមីស*

ប្រទេសអូស្ត្រាលី និងឥណ្ឌាត្រូវបានគេរំពឹងថា នឹងឈានដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបណ្តោះអាសន្ននៅក្នុងខែមីនានេះ ដើម្បីកាត់បន្ថយការពឹងផ្អែកសេដ្ឋកិច្ចរបស់ពួកគេទៅលើប្រទេសចិន ដែលជាមហាអំណាចទី២ក្នុងពិភពលោក។ ការអនុវត្តកិច្ចព្រមព្រៀង

នេះ ដំបូងត្រូវបានប្រើដើម្បីបើកទ្វារពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរកាន់តែទូលំទូលាយសម្រាប់ការនាំចេញនាំចូលទំនិញ និងសេវាកម្ម ដែលវានឹងមានការកាត់បន្ថយពន្ធលើទំនិញមួយចំនួន ព្រមទាំងមានការអនុវត្តនិតិវិធីផ្សេងទៀត មុននឹងឈានដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពេញលេញ។ កិច្ចព្រមព្រៀងនេះ នឹងគ្របដណ្តប់លើទំនិញ សេវាកម្ម ច្បាប់នៃប្រភពដើម និងគោលការណ៍អ្នកប្រើប្រាស់ជាដើម។

ការនាំចេញទំនិញកំពូលរបស់ឥណ្ឌាទៅកាន់ប្រទេសអូស្ត្រាលីក្នុងឆ្នាំ ២០២០ មានដូចជាប្រេង ឱសថ ពេជ្រ និងលោហៈដ៏មានតម្លៃ ខណៈអូស្ត្រាលីបាននាំចេញទៅឥណ្ឌាវិញមានដូចជា ធ្យូងថ្មមានប្រហែល ៨០% នៃការនាំចេញសរុបរបស់អូស្ត្រាលីទៅកាន់ប្រទេសឥណ្ឌា បន្ទាប់មកដោយទង់ដែង និងដែកអេតចាយ។

ប្រទេសចិន គឺជាដៃគូពាណិជ្ជកម្មកំពូលរបស់អូស្ត្រាលី និងជាប្រភពនាំចូលដ៏សំខាន់របស់ឥណ្ឌាផងដែរ។ តែយ៉ាងណាមិញ ប្រទេសទាំងឥណ្ឌា និងអូស្ត្រាលី បានឃើញទំនាក់ទំនងជាមួយនឹងចិន កាន់តែយ៉ាប់យ៉ឺនទៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ដូច្នេះហើយ ទីក្រុងញូវដេលី បច្ចុប្បន្ននេះកំពុងព្យាយាមបង្កើនពាណិជ្ជកម្មវាយនភណ្ឌ និងគ្រឿងអលង្ការជាមួយអូស្ត្រាលី ខណៈពេលដែលទីក្រុងកង់បេរ៉ាវិញ ក៏ស្វែងរកលំហូរពាណិជ្ជកម្មកាន់តែច្រើនលើផលិតផលឱសថ ធ្យូងថ្ម និងរ៉ែកម្រជាមួយឥណ្ឌាផងដែរ។ ទាំងអូស្ត្រាលី និងឥណ្ឌាសុទ្ធតែបានរងការប៉ះទង្គិចពាណិជ្ជកម្មមួយចំនួនជាមួយចិន។ ចំពោះប្រទេសអូស្ត្រាលី ដោយសារការអំពាវនាវរបស់អូស្ត្រាលីឱ្យមានការស៊ើបអង្កេតឯករាជ្យលើប្រភពនៃមេរោគរាតត្បាតកូវីដ១៩ បានបង្កើនភាពតានតឹងជាមួយទីក្រុងប៉េកាំង។ ទើបក្រោយមកប្រទេសចិនបានរឹតបន្តឹងការនាំចូលសាច់គោ និងធ្យូងថ្មរបស់អូស្ត្រាលី ហើយបានដាក់ពន្ធខ្ពស់លើស្រា និងស្រូវសាឡីជដើម។ ដោយឡែក សម្រាប់ឥណ្ឌាវិញ បើទោះបីជាប្រទេសចិនគឺជាប្រភពនាំចូលដ៏ធំបំផុតដែលមានទំហំទឹកប្រាក់ចំនួនជាង ៨៧ ពាន់លានដុល្លារក្នុងឆ្នាំ ២០២១ក៏ពិតមែន ប៉ុន្តែ ដោយសារភាពរកាំរកូសមួយចំនួនបានកើតមាននៅមួយរយៈចុងក្រោយនេះ ពិសេសជម្លោះនៅតាមបណ្តោយព្រំដែនហិម៉ាឡៃរវាងឥណ្ឌា និងចិន ហាក់ធ្វើឱ្យទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរនេះមិនសូវជារលូននោះ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។*

## ប្រមុខអង្គការសហប្រជាជាតិព្រមាន សង្គ្រាមនៅអ៊ុយក្រែននឹងប៉ះពាល់ដល់ប្រព័ន្ធស្បៀងអាហារពិភពលោក



*ដោយ troryorng*

ប្រមុខអង្គសហប្រជាជាតិបានព្រមានថា ពិភពលោកត្រូវតែធ្វើសកម្មភាពដើម្បីការពារ «ព្យុះសង្ឃរានៃភាពអត់ឃ្លាន និង ការបាត់បង់ប្រព័ន្ធស្បៀងអាហារពិភពលោក» បន្ទាប់ពីមានសង្គ្រាមរវាងរុស្ស៊ីលើអ៊ុយក្រែន។ ហានិភ័យនៃសង្គ្រាមនឹងបង្កឱ្យមានផលវិបាកដ៏ធំធេងក្នុងការផ្គត់ផ្គង់ស្បៀងអាហារសកលដែលនឹងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ប្រទេសដែលមានចំណូលទាប។ សង្គ្រាមនេះបានធ្វើឱ្យប៉ះពាល់ដល់ប្រទេសអាហ្វ្រិក និងប្រទេសដែលពឹងផ្អែកលើការនាំចូលស្បៀងអាហារពីប្រទេសទរុស្ស៊ី និងអ៊ុយក្រែន។ ប្រទេសទាំង២នេះ បាន

ផ្គត់ផ្គង់ប្រេងផ្កាឈូករ័ត្នប្រមាណពាក់កណ្តាលពិភពលោក និង ស្រូវសាលី ៣០%ដល់ពិភពលោក។ ដោយអ៊ុយក្រែនតែមួយ បានផ្គត់ផ្គង់ជាងពាក់កណ្តាលនៃការផ្គត់ផ្គង់ស្រូវសាលីរបស់កម្មវិធីស្បៀងអាហារពិភពលោក។ សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់អង្គការសហប្រជាជាតិ គឺស្ថិតក្នុងកម្រិតខ្ពស់បំផុត របស់ពិភពលោកបាននាំចូលស្រូវសាលីយ៉ាងហោចណាស់ ១ភាគ៣ របស់ពួកគេពីអ៊ុយក្រែន ឬ រុស្ស៊ី។ មុនសង្គ្រាមរវាងប្រទេសទាំង ២ផ្ទុះឡើង បណ្តាប្រទេសជាច្រើនកំពុងតែខិតខំតស៊ូងើបសេដ្ឋកិច្ចឡើងវិញពីជំងឺរាតត្បាត។ ដូច្នេះយើងត្រូវតែធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើទៅបាន ដើម្បីបញ្ចៀសព្យុះសង្ឃរានៃភាពអត់ឃ្លាន និង ការបាត់បង់ប្រព័ន្ធស្បៀងអាហារពិភពលោក។ *ដោយ ម៉ែន ខែមវរៈ*

*ប្រភព ៖ troryorng ចេញផ្សាយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។*

## ឥណ្ឌាសម្លឹងឃើញឱកាសទិញប្រេងរុស្ស៊ីក្នុងតម្លៃទាប



*ដោយ ខេមបូណូមីស*

ប្រទេសឥណ្ឌា អាចនឹងទទួលយកការផ្តល់ជូនរបស់រុស្ស៊ី ដើម្បីទិញប្រេងឆៅ និងទំនិញផ្សេងទៀតដោយមានការបញ្ចុះតម្លៃ។ នេះជាសញ្ញាមួយបង្ហាញថាឥណ្ឌាចង់រក្សាមិត្តភាពដៃគូពាណិជ្ជកម្មដ៏សំខាន់ជាមួយរុស្ស៊ី ទោះបីជាលោកខាងលិចព្យាយាមផ្តាច់ទំនាក់ទំនងទីផ្សារចេញពីទីក្រុងមូស្គូ តាមរយៈការដាក់ទណ្ឌកម្មក្តី និងឈប់នាំចេញនាំចូលផលិតផលសំខាន់ពីរុស្ស៊ីក៏ដោយ។ ឥណ្ឌាពឹងផ្អែកការនាំចូលខ្ពស់ពីទីក្រុងមូស្គូ រួមទាំងការផ្គត់ផ្គង់ដូចជា អាវុធ និងគ្រាប់រំសេវកាំជ្រួច និងយន្តហោះចម្បាំងផងនោះ។ ឥឡូវនេះ ឥណ្ឌា កំពុងប្រឈមនឹងប្រេងឡើងថ្លៃ ដោយប្រទេសនេះ មានតម្រូវការប្រេងនាំចូលរហូតដល់៨០% សម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ជាទូទៅឥណ្ឌាទិញប្រេងពីរុស្ស៊ីប្រហែល ២%ទៅ៣% ប៉ុណ្ណោះ។ ក៏ប៉ុន្តែដោយសារតែមកទល់ពេលនេះប្រេងឡើងថ្លៃខ្ពស់ដល់ទៅ ៤០%ទៅហើយនោះ បានជំរុញឱ្យរដ្ឋាភិបាលឥណ្ឌាស្វែងរកការនាំចូលប្រេងពីរុស្ស៊ីបន្ថែម។ រុស្ស៊ី នឹងផ្តល់ ទំនិញជាច្រើនទៀត ជាមួយនឹងការបញ្ចុះតម្លៃយ៉ាងច្រើនសម្រាប់ឥណ្ឌា ហើយរដ្ឋាភិបាលនឹងរីករាយក្នុងការទទួលយកការផ្តល់ជូននេះ។ ក្រៅតែពីប្រេង ឥណ្ឌាក៏ពុងរកមើលទិញជីកសិកម្មក្នុងតម្លៃថោក ពីប្រទេសរុស្ស៊ី និងបេឡារុសផងដែរ។

គេមើលឃើញថា ឥណ្ឌាបានជ្រើសយកការដើរលើផ្លូវកណ្តាល នៅក្នុងបញ្ហាសង្គ្រាមនៅអ៊ុយក្រែននេះ ដោយកន្លងមកឥណ្ឌាមិនបានចេញថ្កោលទោសរុស្ស៊ី លើការឈ្លានពានអ៊ុយក្រែនទេ ហើយឥណ្ឌាថែមទាំងបានបោះឆ្នោតអនុប្បវាទនៅអង្គការសហប្រជាជាតិ ស្តីអំពីការទាមទារឱ្យរុស្ស៊ីបញ្ឈប់សង្គ្រាម និងដកទ័ពចេញពីអ៊ុយក្រែនផងដែរ។ ឥណ្ឌា និងរុស្ស៊ី បានកសាងទំនាក់ទំនងជាច្រើនឆ្នាំមកហើយ ដោយឥណ្ឌាមានការពឹងផ្អែកលើរុស្ស៊ីសម្រាប់ការផ្គត់ផ្គង់សព្វាវុធរហូតដល់ ៦០% ទោះបីជាមានការថយចុះគួរឱ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយក៏ដោយ៕ *ដោយ ម៉ែន ខែមវរៈ*

*ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២១ ខែមីនា ឆ្នាំ២០២២

- កំណើនចំនួនជនបរទេសដែលមកទស្សនា ក្នុងខែមករា ឆ្នាំ 2022 ធៀបនឹងឆ្នាំមុន
- បំណុលរដ្ឋាភិបាលនៅក្នុងប្រទេសទួរគី បាន កើនឡើង នៅក្នុងខែមករា

ថ្ងៃអង្គារ ទី២២ ខែមីនា ឆ្នាំ២០២២

- ការចំណាយរបស់អតិថិជននៅម៉ិកស៊ិក បាន កើនឡើង ក្នុងត្រីមាសទីបីនៃឆ្នាំ 2021
- តម្រូវការសរុប GDP នៅក្នុងប្រទេសម៉ិកស៊ិក បានធ្លាក់ចុះមកត្រឹម 0.30% នៅក្នុងត្រីមាសទី 3 ឆ្នាំ 2021

ថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០២២

- អត្រាអតិផរណាប្រចាំឆ្នាំនៅចក្រភពអង់គ្លេស បានកើនឡើងខ្ពស់ ក្នុងខែមករា ឆ្នាំ 2022
- តម្លៃទំនិញប្រើប្រាស់នៅអាហ្វ្រិកខាងត្បូង បាន កើនឡើង 0.2% ក្នុងខែមករា ឆ្នាំ 2022

ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមីនា ឆ្នាំ២០២២

- អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសអាហ្សង់ទីនបានថយចុះមកត្រឹម 8.2%នៅក្នុងត្រីមាសទី 3 ឆ្នាំ 2021 ពី 9.6%នៅក្នុងរយៈពេលមុន
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអារ៉ាប៊ីសាអូឌីតបានកើនឡើង ក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២

- ការប៉ាន់ប្រមាណបឋម សេដ្ឋកិច្ចរបស់ប្រទេសអេស្ប៉ាញបានកើនឡើង2.0 %នៅត្រីមាសក្នុងរយៈពេល 3 ខែចុងក្រោយនៃឆ្នាំ 2021
- ថវិការដ្ឋាភិបាលរបស់ប្រទេសកាណាដា បានប្តូរទៅជាអតិរេកក្នុងខែធ្នូ ឆ្នាំ 2021 ពីឱនភាពក្នុងខែដូចគ្នានៃឆ្នាំមុន៕